ភ្នំពេញ , ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ១៩៩៣

# សេចក្តីសំរេចលេខ ០៣ សសរ ស្តីពីការផ្ទេរ អាគាររបស់មន្ទីរហិរញ្ញវត្ថុក្រុងភ្នំពេញជូនក្រសួង អភិវឌ្ឍន៍ជនបទ ដើម្បីធ្វើជាទីស្តីការក្រសួង

៚៚៚៚

## រដ្ឋាភិបាលជាតិបណ្តោះអាសន្នកម្ពុជា

- បានឃើញក្រឹត្យចុះថ្ងៃទី ០២ ខែ កក្កដា ឆ្នាំ ១៩៩៣ របស់សម្តេចព្រះឧបយុវរាជ នរោត្តម សីហនុ ព្រះប្រមុខរដ្ឋនៃកម្ពុជា ស្តីពីការតែងតាំងរដ្ឋាភិបាលជាតិបណ្តោះអាសន្ននៃកម្ពុជា

**សំរេច**

ប្រការ ១ : ផ្ទេរអាគាររបស់មន្ទីរហិរញ្ញវត្ថុក្រុងភ្នំពេញ ជូនក្រសួងអភិវឌ្ឍន៍ជនបទ ដើម្បីធ្វើជាទីស្តីការរបស់ក្រសួង ។ អាគារនេះស្ថិតនៅទទឹងថ្ងៃ ខាងលិចទីស្តីការគណៈរដ្ឋមន្ត្រីនៅកែងផ្លូវ ហ៊្សុកឌីមីត្រូហ្វ និង ផ្លូវលេខ ១៦៩។

ប្រការ ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ និងលោកអភិបាលរដ្ឋធានីភ្នំពេញ មានភារកិច្ច អនុវត្តសេចក្តីសំរេចនេះ ចាប់ពីថ្ងៃ ចុះហត្ថលេខាតទៅ។

**ត.ប សហប្រធាន**

នៃរដ្ឋាភិបាលជាតិបណ្តោះអាសន្នកម្ពុជា

ហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**

**តាគ ឈន់**

✻✻✻✻